**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការរៀបចំពិធីបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធកម្មាភិបាលយុទ្ធជន និងបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់-ជួសជុលទីលានផ្នូរយុទ្ធជន ខេត្តកោះកុង

គណៈកម្មការសាងសង់-ជួសជុលទីលានផ្នូរយុទ្ធជន និងរដ្ឋបាលខេត្តកោះកុង មានកិត្តិយស សូមទូលប្រគេន-គោរពជម្រាបជូនដំណឹងដល់ **សម្ដេច ទ្រង់ ព្រះមន្ត្រីសង្ឃគ្រប់ឋានានុក្រម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សប្បុរសជន និងក្រុមគ្រួសារនៃសព** យុទ្ធជនជិតឆ្ងាយទាំងអស់ សូមព្រះមេត្តា-មេត្តាជ្រាបថា៖ គណៈកម្មការសាងសង់-ជួសជុលទីលានផ្នូរយុទ្ធជន និងរដ្ឋបាលខេត្តកោះកុង នឹងរៀបចំពិធីបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធកម្មាភិបាលយុទ្ធជន ដែលបានពលីជីវិតក្នុងសម័យសង្គ្រាមចាប់ពីឆ្នាំ១៩៧៩ ដល់ចុងឆ្នាំ១៩៩៨ និងបានបញ្ចុះនៅទីនេះ**ចំនួន៤៤៧សព** ដែលមានស្រុកកំណើតមកពី១៨ រាជធានី ខេត្ត ព្រមទាំងឧទ្ទិសកុសលដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន វីរជនស្នេហាជាតិទាំងអស់ ដែលបានពលីជីវិតក្នុងបុព្វហេតុជាតិ និងពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់-ជួសជុលទីលានផ្នូរយុទ្ធជន ខេត្តកោះកុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង និង**លោកជំទាវ** ។

កម្មវិធីនឹងប្រព្រឹត្តទៅរយៈពេល២ថ្ងៃគឺ ថ្ងៃចន្ទ-អង្គារ១១-១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២២-២៣ ខែកុម្ភៈ ឆ្នាំ២០២១ នៅទីលានផ្នូរយុទ្ធជនខេត្តកោះកុង (សពយុទ្ធជន) ស្ថិតនៅក្នុងភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដែលប្រព្រឹត្តទៅដូចខាងក្រោម៖

**-នៅរសៀលថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង១៤:៣០នាទី** រៀបចំពិធីក្រុងពាលី និងនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត សម្ដែងព្រះធម៌ទេសនា ។

**-នៅព្រឹកថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១**

- ម៉ោង៨:០០នាទីព្រឹក ព្រះសង្ឃ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋជួបជុំនៅកន្លែងប្រារព្ធពិធី
- ម៉ោង៨:៣០នាទីព្រឹក គណៈអធិបតី ភ្ញៀវកិត្តិយស អញ្ជើញដល់កន្លែងប្រារព្ធពិធី
- ម៉ោង៩:០០នាទីព្រឹក ពិធីសំណេះសំណាល និងប្រគេន-ប្រគល់ជូនប័ណ្ណថ្លែងអំណរគុណដល់សប្បុរសជន ដែលបានបរិច្ចាគថវិកាចូលរួមជួយឧបត្ថម្ភដល់ការសាងសង់-ជួសជុលទីលានផ្នូរយុទ្ធជនខេត្តកោះកុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។

សេចក្ដីជូនដំណឹងនេះ ចាត់ទុកជាការនិមន្ត-គោរពអញ្ជើញ និងអំពាវនាវចំពោះ **សម្ដេច ទ្រង់ ព្រះមន្ត្រីសង្ឃគ្រប់ឋានានុក្រម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា ឧកញ៉ា លោក លោកស្រី សប្បុរសជន និងក្រុមគ្រួសារនៃសព** យុទ្ធជនជិតឆ្ងាយទាំងអស់ ព្រះមេត្តា-មេត្តាចូលរួមឧបត្ថម្ភគាំទ្រថវិកាទៅតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន ដើម្បីចូលចំណែកដល់ការសាងសង់-ជួសជុលទីលានផ្នូរយុទ្ធជនខេត្តកោះកុងឲ្យសម្រេចបានជាស្ថាពរ។

ថ្ងៃ...ចន្ទ ៤ កើត... ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
កោះកុង, ថ្ងៃទី...១៥....ខែ...កុម្ភៈ ឆ្នាំ២០២១
**ប្រធានគណៈកម្មការសាងសង់**

នាយឧត្តមសេនីយ៍ យន_មីន

***លេខទំនាក់ទំនង៖***

- 097 96 11 625
- 097 32 32 233
- 097 66 94 511
- 068 99 33 55